

# ភាពសាមញ្ញ ស្ដីពី រ៉េដ

## ការបង្ហាញរបស់ CIFOR អំពីព្រៃឈើ
## ការប្រែប្រួលអាកាសធាតុ និង រ៉េដ

សំគាល់: ឯកសារនេះរៀបចំឡើងដោយ CIFOR ប៉ុន្តែត្រូវបានធ្វើការបកប្រែដោយបុគ្គលិកអង្គការ Pact កម្ពុជា។

អង្គការ Pact កម្ពុជា មិនធ្វើការធានាលើការបកប្រែ និងមិនមានចេតនាកែតំរូវអត្ថន័យឡើយ។

នៅពេលដែលមនុស្សជជែកគ្នាអំពីការប្រែប្រួលអាកាសធាតុពួកគេតែងតែប្រើប្រាស់ភាសាបច្ចេកទេស និង ពាក្យវិទ្យាសាស្ត្រ ហើយពាក្យ និងវាក្យសព្ទដែលយើងបានឮអាចធ្វើឱ្យមានភាពស្មុគស្មាញ ដោយសារតែយើងមិនយល់ពីអត្ថន័យនៃពាក្យទាំងនោះ។

CIFOR បានធ្វើការរៀបចំនូវឯកសារណែនាំ ដែលមានលក្ខណៈងាយស្រួល ដើម្បីជួយអ្នកសារពត៌មាន អ្នកនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និង ប្រជាជននៅក្នុងពិភពលោកអោយមាន ការយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃព្រៃឈើក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ ឯកសារនេះ នឹងបង្ហាញអំពីចំនុចសំខាន់ៗ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុពិភពលោក ព្រមជាមួយដំណោះស្រាយដែលមានប្រសិទ្ធភាព ប្រសិទ្ធផល និងប្រកបដោយសមធម៌ ។

## ស១: ហេតុអ្វីយើងត្រូវការពារព្រៃឈើ ប្រសិនបើយើងចង់កាត់បន្ថយការប្រែប្រួលអាកាសធាតុ?

**ច១:** អ្នកវិទ្យាសាស្ត្របានធ្វើការប៉ាន់ប្រមាណថាប្រហែល២០ភាគរយនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ ប្រចាំឆ្នាំទៅក្នុងបរិយាកាសគឺបណ្តាលមកពីការបាត់បង់ និងការថយចុះព្រៃឈើ។ ការបំភាយនេះគឺច្រើនជាងការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលចេញមកពីវិស័យដឹកជញ្ជូនទូទាំងសកលលោក។

## ស២: ហេតុអ្វីបានជាការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលចេញពីព្រៃឈើច្រើនជាងការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលចេញពី រថយន្តតូច រថយន្តដឹកទំនិញ យន្តហោះ និង កប៉ាល់រួមបញ្ចូលគ្នា?

**ច២:** ពេលព្រៃឈើទទួលរងការបំផ្លិចបំផ្លាញ ការដុតកំទេច ឬ ទទួលរងការពុកផុយ កាបូនដែលមាននៅ ក្នុងដើមឈើទាំងនោះបានបញ្ចេញទៅខាងក្រៅបរិយាកាសក្នុងទំរង់ជាឧស្ម័នកាបូនិច ហើយវានឹងធ្វើអោយមានការកើនឡើងនូវកំរិតកំដៅបរិយាកាស ការរាំងខ្ទប់កំដៅដែលមាននៅក្នុងផែនដីនេះហៅថា ឧស្ម័នផ្ទះកញ្ចក់ ។ ជាងនេះទៅទៀត ព្រៃឈើមួយចំនួនធំបានផ្ទុកបរិមាណកាបូនដ៏ច្រើននៅស្រទាប់ក្រោមដី។

**ឧទាហរណ៍:** នៅពេលដែលគេដុតព្រៃឈើនៅក្នុងតំបន់ ដែលសំបូរទៅដោយរុក្ខជាតិពុកផុយ (Peatland)នោះវាធ្វើអោយមានការបញ្ចេញឧស្ម័នកាបូនិចពីក្នុងដីដ៏ច្រើនឥតគណនា ហើយអតិសុខុមប្រាណដែលមាននៅក្នុងដីក៏បំភាយឧស្ម័នកាបូនិចផងដែរ។ ព្រៃដុះនៅក្នុងតំបន់ ដែលសំបូរទៅដោយរុក្ខជាតិពុកផុយ មានផ្ទុកនូវបរិមាណ

កាបូននៅស្រទាប់ក្រោមដីច្រើនជាងស្រទាប់លើដី។ កាបូនទាំងនេះ និងលេចធ្លាយចេញទៅក្នុងបរិយាកាស ប្រសិនបើដើមឈើទាំងនោះត្រូវបានគេកាប់បំផ្លាញ។ នៅពេលដែលព្រៃឈើបាត់បង់ ផែនដីក៏បាត់បង់នូវធនធាន ដ៏សំខាន់ដែលធ្លាប់ស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។ ការសិក្សាថ្មីៗ បានរកឃើញថាព្រៃឈើបានស្រូបឧស្ម័នកាបូនិច ៥កោដិ តោននៃឧស្ម័នកាបូនិច ៣២កោដិ តោន ដែលបានបំភាយប្រចាំឆ្នាំទៅក្នុងស្រទាប់បរិយាកាស តាមរយៈសកម្មភាពមនុស្ស ។ ដូចនេះពេលផែនដីបាត់បង់ដើមឈើ គឺការបាត់បង់ទ្វេនគ្នា ៖យើងបាត់បង់នូវប្រព័ន្ធអេកូឡូស៊ី ដែលស្រូបយកឧស្ម័នផ្ទះកញ្ចក់ពីបរិយាកាស និងយើងបាត់បង់នូវដើមឈើ ដែលផ្ទុកនូវកាបូនផងដែរ។

## សៈ៧: តើវានឹងអាចមានអ្វីកើតឡើង? តើយើងគួរបោះបង់ការពារព្រៃឈើទាំងអស់នោះឬ?

**ចៈ៧:** ទេ ព្រៃឈើបានចិញ្ចឹមជីវិតមនុស្សរស់នៅក្នុងនិងជុំវិញវា និងសង្គមទាំងមូល។ តាមប្រភពព័ត៌មានរបស់ធនាគារពិភពលោកបានបង្ហាញថាប្រជាជនជាងមួយកោដិនាក់បានពឹងអាស្រ័យទៅលើព្រៃឈើ យ៉ាងខ្លាំងសំរាប់ការរស់នៅរបស់ពួកគេ។ ប្រជាជនរាប់រយលាននាក់បានពឹងផ្អែកលើការប្រមូលឱសថចេញមកពីព្រៃឈើសំរាប់ការថែរក្សាសុខភាព។ ក្នុងនោះ ការបរបាញ់ ការនេសាទត្រី ដែលមាននៅក្នុងតំបន់ព្រៃឈើបានជួយយ៉ាងច្រើនទៅលើក៏រិតប្រូតេអ៊ីនសំរាប់សហគមន៍ជនបទ។ ព្រៃឈើកាន់តែមានតួនាទីដ៏សារៈសំខាន់ នៅក្នុងទស្សនៈវិស័យពាណិជ្ជកម្ម។ នៅក្នុងឆ្នាំ ២០០៣ ពាណិជ្ជកម្មអន្តរជាតិផ្នែក ឈើអារ ឈើកិន ក្រដាស និងក្តារ បន្ទះ មានតំលៃរហូតដល់ ១៥០កោដិលានដុល្លា គឺប្រមាណជា២ភាគរយនៃ ពាណិជ្ជកម្មពិភពលោក។ យើងអាចរំពឹងថាការបំលែងដីព្រៃឈើទៅជាដីកសិកម្មនឹងនៅតែមានបន្ត ប៉ុន្តែការបំលែងនេះគួរតែមាន លក្ខណៈសមស្រប និងនិរន្តរភាព។ ការកាប់ឈើ ការគាស់រំលីង និង ការដុតព្រៃតំបន់ត្រូពិចដោយអាណាធិតេយ្យត្រូវតែបញ្ចប់ ។

## សៈ៨: ប្រសិនបើយើងទប់ស្កាត់ការកាប់ព្រៃឈើ តើមានអ្នកបាត់បង់ផលប្រយោជន៍ឬទេ?

**ចៈ៨:** ព្រៃឈើជាធម្មតាត្រូវបានកាប់រំលើងដោយសារតែមនុស្សអាចទាញផលជាលុយពីសកម្មភាពទាំងអស់នោះ។ ការបំលែងពីដីព្រៃទៅជាដីដំណាំឧស្សាហកម្មសម្រាប់លក់ ដូចជាដំណាំដូងប្រេងជាដើមអាចបង្កើតប្រាក់ចំណេញច្រើន។ អ្នកដែលពឹងអាស្រ័យលើព្រៃឈើមិនគួរទទួលរងគ្រោះទេ បើយើងគិតអោយបានយូរអង្វែងទៅមនុស្សទាំងអស់ នឹងទទួលបានសារៈប្រយោជន៍ពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ប្រសិនបើឧស្ម័នផ្ទះកញ្ចក់ ដែលបានផ្ទុកនៅក្នុងព្រៃឈើត្រូវបានបញ្ចេញទៅក្នុងបរិយាកាស វានឹងទាមទាររយៈពេលរាប់

ជំនាន់ក្នុងចាប់យកឧស្ម័នទាំងនោះត្រលប់មកវិញបាន ។ ដូចនេះប្រសិនបើព្រៃឈើនៅតែបន្តបាត់បង់នោះ យើងនឹងជួបគ្រោះមហន្តរាយមួយដ៏អាក្រក់ ។

## ស៥: តើនឹងមានគ្រោះមហន្តរាយអ្វីខ្លះដែលនឹងកើតឡើងនោះ?

**ច៥:** នៅពេលគេកាប់បំផ្លាញព្រៃឈើច្រើនធ្វើអោយអាកាសធាតុកាន់តែក្តៅទៅៗ អាកាសធាតុក្តៅធ្វើ ឱ្យមានភាពរាំងស្ងួត ភ្លើងឆេះព្រៃច្រើនហើយបញ្ចេញឧស្ម័នកាបូនិចបន្ថែមទៀតទៅក្នុងបរិយាកាស នឹងកាន់តែធ្វើឱ្យស្ថានភាពកាន់តែមានគ្រោះមហន្តរាយទ្វេដង ដូចនេះប្រសិនបើយើងមិនធ្វើការទប់ស្កាត់ការបាត់បង់ព្រៃឈើភ្លាមៗនោះទេ ព្រៃឈើនឹងបាត់បង់លទ្ធភាពនៅក្នុងការជួយបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ។

## ស៦: តើគួរតែធ្វើអ្វីខ្លះ?

**ច៦:** មានការងារវិជ្ជមានជាច្រើនកំពុងតែត្រូវបានធ្វើ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុតាមរយៈការអភិរក្សព្រៃឈើ ការសិក្សាស្រាវជ្រាវផ្តោតទៅលើដំណើរការពីរគឺ ភាពបន្សាំ និង ការបន្ធូរបន្ថយ។

## ស៧: អ្វីទៅគឺជាភាពបន្សាំ?

**ច៧:** នៅពេលមានការប្រែប្រួលអាកាសធាតុ ព្រៃឈើ និង មនុស្សត្រូវតែចេះសម្របខ្លួន នឹងសីតុណ្ហភាពអាកាសធាតុ និង ទឹកភ្លៀង ។ នៅពេលអនាគតពិភពលោកនឹងជួបគ្រោះរាំងស្ងួត ទឹកជំនន់ កាន់តែច្រើន និងកាន់តែធ្ងន់ធ្ងរ។ ការបន្សាំអាចជួយអោយមនុស្សរៀបចំខ្លួនជាមុនសំរាប់សម្របខ្លួនទៅនឹងគ្រោះមហន្តរាយទាំងនោះបាន និងរក្សាស្ថានភាពរស់នៅរបស់ពួកគេ ។

## ស៨: តើអ្វីដែលជាឧទាហរណ៍របស់គំរោងនៃភាពបន្សាំ?

**ច៨:** នេះជាចំណុចថ្មីមួយ នៃការសិក្សាស្រាវជ្រាវអំពីនយោបាយព្រៃឈើ ដែលមានឧទាហរណ៍ដូចខាងក្រោម :

- គំរោងការពារព្រៃឈើនៅក្នុងតំបន់ទីជំរាល ដើម្បីទប់ស្កាត់ការហូរច្រោះកើតឡើងដោយសារទឹកភ្លៀងច្រើន
- គំរោងការពារច្រករបៀងព្រៃឈើ ដើម្បីអោយសត្វព្រៃ និង រុក្ខជាតិមានលទ្ធភាពក្នុងការផ្លាស់ទីទៅកន្លែង ដែលមានសីតុណ្ហភាពសមស្រប

- គំរោងរៀបចំតំបន់ទ្រនាប់ដើម្បីបញ្ឈប់ការរីករាលដាលនៃភ្លើងព្រៃ
- គំរោងដាំប្រភេទឈើ ដែលធន់ទៅនឹងសីតុណ្ហភាពខ្ពស់ និង បាតុភូតធាតុអាកាសអាក្រក់ៗ។

វិស័យជាច្រើនគឺមានការទាក់ទងទៅនឹងនយោបាយនៃភាពបន្សាំ ។ **ឧទាហរណ៍:** ក្រសួងគមនាគមន៍មានការចាប់អារម្មណ៍លើការដាំដើមឈើអោយបានល្អពីព្រោះផ្សែង ដែលចេញពីភ្លើងព្រៃអាចប៉ះពាល់ដល់ការបិទជើងហោះហើរ និង មានការបាក់ដីដែលអាចបណ្តាលអោយមានបិទផ្លូវចរាចរ។ **ឧទាហរណ៍:** អ្នកផ្គត់ផ្គង់ទឹកស្អាត និង ក្រុមហ៊ុនវារីអគ្គីសនីកំពុងចាប់ផ្តើមធ្វើការពិចារណាទៅលើការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីនៅផ្នែកខាងលើរួមទាំងការគ្រប់គ្រងព្រៃឈើ ពីព្រោះពួកគេចង់កាត់បន្ថយភាពងាយរងគ្រោះ ដោយសារតែការប្រែប្រួលរបបទឹកភ្លៀង និង ធានាថាគុណភាព និងបរិមាណទឹករបស់ពួកគេអាចផ្គត់ផ្គង់គ្រប់គ្រាន់ ។

## ស៩: អ្វីទៅជាការបន្ធូរបន្ថយ?

**ច៩:** ភាពបន្សាំ និង ការបន្ធូរបន្ថយ គឺមានការបំពេញឱ្យគ្នាទៅវិញទៅមក ។ ភាពបន្សាំ គឺទាក់ទងទៅនឹងការដោះស្រាយនូវផលវិបាកនៃការប្រែប្រួលអាកាសធាតុ រីឯការបន្ធូរបន្ថយមានបំណងដោះស្រាយបញ្ហា ដែលបង្កអោយមានការប្រែប្រួលអាកាសធាតុ។ យើងត្រូវការយុទ្ធសាស្ត្រទាំងពីរនេះ ពីព្រោះអ្នកវិទ្យាសាស្ត្របានគិតទុកថាទោះបីយើងបញ្ឈប់ការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ភ្លាមៗក៏ដោយ ប៉ុន្តែការកើនឡើងនូវកំដៅនៅតែមានបន្តមួយរយៈពេលទៀត នេះដោយសារតែការបន្សល់ពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីមុនមក។

## ស១០: តើយើងត្រូវធ្វើដូចម្តេចដើម្បី កាត់បន្ថយល្បឿននៃការប្រែប្រួលអាកាសធាតុ?

**ច១០:** ប្រសិនបើចង់អោយមានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ប្រទេសអភិវឌ្ឍន៍ត្រូវតែកាត់បន្ថយការប្រើប្រាស់ឥន្ធនៈ។ ក្នុងនោះដែរការដាំដើមឈើដើម្បីស្រូបយកកាបូនបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ប៉ុន្តែដើម្បីកាត់បន្ថយការបញ្ចេញចោល ២០ភាគរយនៃឧស្ម័នកាបូនិចចេញពីការបាត់បង់ព្រៃឈើ យើងត្រូវមានយុទ្ធសាស្ត្រថ្មីដើម្បីអភិរក្សព្រៃឈើ ។ មានវិធីសាស្ត្រមួយ គេហៅថា **រ៉េដ** (REDD) មានន័យថា ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលចេញមកពីការបាត់បង់ព្រៃឈើ និង ការថយចុះនៃព្រៃឈើ។ គំនិតថ្មីនេះ ខុសពីការការពារព្រៃឈើពីមុនៗ ដោយសារការពារព្រៃឈើដែលមានផ្ទុកកាបូនមានភ្ជាប់ជាមួយការគាំទ្រថវិកានៅក្នុងសកម្មភាពនៃការពារ ។

## ស១១: តើ REDD នឹងដំណើរការយ៉ាងដូចម្តេច?

**ច១១:** ឥណទានកាបោនបានមកពីការស្រូប និង ផ្ទុកឧស្ម័នផ្ទះកញ្ចក់ដោយព្រៃឈើ ត្រូវបានគេលក់នៅទីផ្សារកាបូនអន្តរជាតិ។ ម្យ៉ាងវិញទៀត ការទូទាត់សងឥណទានកាបូននេះអាចធ្វើទៅបានតាមរយៈមូលនិធិអន្តរជាតិដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការទូទាត់សងថវិកាសំរាប់ប្រទេសអ្នកចូលរួមអភិរក្សព្រៃឈើរបស់គេ។ គំនិតនោះគឺថារេដ (REDD) អាចធ្វើអោយការការពារព្រៃឈើមានតំលៃខ្ពស់ជាងមុន និងអាចប្រកួតប្រជែងជាមួយនឹងការកាប់បំផ្លាញព្រៃឈើ។ ពេលបច្ចុប្បន្ននេះ ការរីកចំរើនសេដ្ឋកិច្ចមានឥទ្ធិពលទៅលើការបាត់បង់ព្រៃឈើ ដូចជាការកែប្រែដី ព្រៃឈើទៅជាដីកសិកម្ម និង ដីសំរាប់ចិញ្ចឹមសត្វ ។

## ស១២: តើមានបញ្ហាអ្វីខ្លះនៅក្នុងការអនុវត្ត REDD?

**ច១២:** មានបញ្ហាប្រឈមចំបងចំនួន៤ដូចខាងក្រោម :

- **ការវាស់វែង**

  ដើម្បីគណនាតំលៃកាបោននៅក្នុងព្រៃណាមួយ យើងត្រូវចេះវាស់កាបូនអោយមានភាពជាក់លាក់នៅទីកន្លែងនោះ។ បច្ចេកវិទ្យាថ្មីៗ ដូចជាតាមរយៈរូបភាពផ្កាយរណប និង កុំព្យូទ័រ កំពុងធ្វើអោយដំណើរការនៃការវាស់វែងកាបូនកាន់តែឆាប់រហ័ស និង ត្រឹមត្រូវ។ ប្រព័ន្ធគណនាកាបូនប្រកបដោយតម្លាភាពក្នុងការវាស់វែង និងផ្ទៀងផ្ទាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ អាចទទួលយកបាននាពេលបច្ចុប្បន្ន។

- **ការទូទាត់សង**

  តើប្រទេសទាំងអស់ទទួលការទូទាត់សងតាមរបៀបណា និង តាមទម្រង់យ៉ាងដូចម្តេចខ្លះ? តើអ្នកណាគួរតែទទួលការទូទាត់សងសម្រាប់កិច្ចការពារព្រៃឈើនៅក្នុងតំបន់ជាក់លាក់ណាមួយ? គួរតែផ្តល់ជូនរដ្ឋាភិបាល? សហគមន៍មូលដ្ឋាន? ឬក៏សម្រាប់ក្រុមហ៊ុនដែលកាប់ព្រៃឈើ? ប្រទេសអ្នកផ្តល់ជំនួយកំពុងតែសុំអោយការទូទាត់សងគួរតែផ្តល់ផលប្រយោជន៍ទៅអោយប្រជាជនក្រីក្រ ។ ប៉ុន្តែរដ្ឋាភិបាលក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនចង់រក្សាការគាំទ្រទៅលើការទូទាត់សងពីកម្មវិធី REDD ។

- **ការទទួលខុសត្រូវ**

  ប្រសិនបើការទូទាត់នៃកម្មវិធី REDD ត្រូវគេបង្កើតឡើងប៉ុន្តែព្រៃឈើនៅតែបន្តការកាប់បំផ្លាញនោះថាតើយើងគួរធ្វើដូចម្តេច?

  តើគួរធ្វើដូចម្តេចដើម្បីធានាថាការទូទាត់កាបូននាំមកនូវកិច្ចការពារព្រៃឈើប្រកបដោយនិរន្តភាព?

- **ការផ្តល់មូលនិធិ**

  តើប្រទេសអភិវឌ្ឍន៍គួរតែបង្កើតមូលនិធិដើម្បីផ្តល់ជារង្វាន់លើកទឹកចិត្តដល់ប្រទេសដែលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការកាប់ព្រៃឈើដែរឬទេ? ហើយការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះគួរតែជាប់ ទាក់ទងទៅនឹងប្រព័ន្ធពាណិជ្ជកម្មទីផ្សារកាបូនដែរឬទេ? ថាតើដំណើរការទីផ្សារធ្វើឡើងតាមរបៀបណា? អ្នកស្រាវជ្រាវ និងអ្នកធ្វើគោលនយោបាយគិតថាកម្មវិធី REDD មិនអាចអនុវត្តជាសកលបានទេ ។ មធ្យោបាយមួយដ៏ប្រសើរបំផុតគឺត្រូវបង្កើតកម្មវិធី REDD ដែលមានគំរូអនុវត្តន៍ផ្សេងៗ គ្នាទៅតាមល័ក្ខខ័ណ្ឌប្រទេសរៀងៗខ្លួន ។

## ស១៣: តើយើងត្រូវធ្វើដូចម្តេចចំពោះសម្លេង និងសិទ្ធិរបស់ជនជាតិដើមភាគតិចដែលពឹងផ្អែកទៅលើព្រៃឈើ?

**ច១៣:** សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍មូលដ្ឋាន គឺជាក្រុមគោលដៅដ៏សំខាន់នៅក្នុងការអនុវត្តកម្មវិធី REDD ។ យើងត្រូវខិតខំប្រឹងប្រែងដើម្បីទទួលស្គាល់ និងការពារសិទ្ធិលើការគ្រប់គ្រងដីធ្លី និងធនធានរបស់សហគមន៍ ។ បើសិនសិទ្ធិរបស់សហគមន៍មិនច្បាស់លាស់ទេ នឹងបណ្តាលឱ្យមានហានិភ័យ ក្នុងការបែងចែកផលប្រយោជន៍ពីកំរៃដែលទទួលបានពីការលក់ឥណទានកាបោនព្រៃឈើ ។ ការរៀបចំគំរោង REDD គួរតែដោះស្រាយអោយបានពេញលេញនូវសិទ្ធិនៃការគ្រប់គ្រងព្រៃឈើរបស់សហគមន៍មូលដ្ឋានមុនការអនុវត្ត គំរោង REDD ។

## ស១៤: តើហេតុអ្វីបានជាគេយកកម្មវិធី REDD មកធ្វើជាប្រធានបទពិភាក្សានៅថ្នាក់អន្តរជាតិ?

**ច១៤:** អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងសន្និសិទ្ធិលើកទី១៣ បណ្តាភាគីជាសមាជិក (UNFCC–COP-13) ក្នុងក្រុងបាលី( ប្រទេសឥណ្ឌូនេស៊ី) ឆ្នាំ២០០៧ កន្លងមកបានបង្កើតផែនការសកម្មភាពបាលី (Bali Action on Plan) ជាដំណើរការមួយសំរាប់ចរចារពីយុទ្ធសាស្ត្រអាកាសធាតុពិភពលោក ដើម្បីបន្តពិធីសាក្យូតូ (Kyoto Protocol) ។ ផែនការនេះបានទទួលស្គាល់ពីសារៈសំខាន់របស់ព្រៃឈើក្នុងការដោះស្រាយការផ្លាស់ប្តូរអាកាសធាតុ និងជាពិសេសសក្តានុពលនៃកម្មវិធី REDD ដ៏ធំទូលាយមួយ ។ កម្មវិធី REDD អាចជួយដោះស្រាយការប្រែប្រួលអាកាសធាតុផង និង ផ្តល់សារៈប្រយោជន៍ផ្សេងៗ

ទៀត **ឧទាហរណ៍** ការការពារជីវៈចំរុះ ប្រភពទឹកនៅក្នុងដីព្រៃ ធ្វើអោយប្រសើរឡើងនូវជីវភាពរបស់សហគមន៍មូលដ្ឋាន និង ការបញ្ជាក់លើកម្មសិទ្ធដីធ្លី។ កិច្ចព្រមព្រាងកូពិនហាហ្គេន (Copenhagen Accords) បានបញ្ជាក់យ៉ាងច្បាស់ថាកម្មវិធីរ៉េដផ្លាស (REDD+) នឹងធ្វើជាផ្នែកមួយនៃយុទ្ធសាស្ត្រនៃការបន្ធូបន្ថយការប្រែប្រួលអាកាសធាតុ ហើយនឹងត្រូវបានគេយកទៅអនុវត្តអោយស្ថិតនៅក្រោមពិធីសាមួយថ្មីទៀតបន្ទាប់ពីពិធីសាក្យូតូបានបញ្ចប់ ។

## ស១៥: តើមានការរីកចំរើនអ្វីខ្លះក្នុងការចរចារថាសាកលស្តីពីកម្មវិធី REDD?

**ច១៥:** នៅក្នុងខែធ្នូ ឆ្នាំ២០០៩ បានបង្ហាញអោយឃើញនូវការបញ្ចប់នៃការពិគ្រោះយោបល់ចំនួនរយៈពេលពីរឆ្នាំ។ អ្នកចរចាររបស់អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC-COP) នៅទីក្រុង**កូពិនហាហ្គេន** (Copenhagen) នឹងសំរេចថាតើយន្តការ REDD ត្រូវគេបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុជាសាកលក្រោយឆ្នាំ ២០១២ ដែរ ឬទេ។ អ្នកចរចារទាំងអស់នោះទំនងជានឹងឈានទៅដល់កិច្ចព្រមព្រៀងជាទូទៅមួយ ដែលអាចបញ្ចូលទាំងកម្មវិធី REDD និងធ្វើការកំណត់នូវទំហំ និងដែនកំណត់របស់វា ប៉ុន្តែបានកំណត់នូវកាលវិភាគលំអិតស្តីពីការពិភាក្សាទៅលើវិធីសាស្ត្រ និងបច្ចេកទេសនៅក្នុងកិច្ចចរចារពេលក្រោយទៀត។ ដំណើរការនេះ គឺដូចអ្វីដែលបានកើតឡើងនៅពេល ដែលគេធ្វើពិភាក្សាទៅចំនុចជាច្រើននៅក្នុងពិធីសាក្យូតូ (Kyoto Protocol) ។

## ស១៦: តើកម្មវិធី រ៉េដផ្លាស (REDD+) មានន័យដូចម្តេច?

**ច១៦:** នៅពេល ដែលមានកិច្ចព្រមពៀងលើផែនការសកម្មភាពនៅទីក្រុងបាលី (Bali Action on Plan) មួយឆ្នាំក្រោយមក អ្នកចរចារស្តីពីការប្រែប្រួលអាកាសធាតុបានជួបជុំគ្នាម្តងទៀត នៅទីក្រុង Poznan នៃប្រទេសប៉ូឡូញ។ ពួកគេបានឈានទៅដល់ សេចក្តីព្រមព្រៀងជារួមមួយ ដោយបញ្ជាក់ថាសកម្មភាពរបស់កម្មវិធី REDD គួរតែពង្រីកថែមទៀត។ វិធាននេះ គេហៅថា REDD+ (REDD-Plus) ។ REDD+ រួមបញ្ចូលផ្នែកយុទ្ធសាស្ត្រដូចខាងក្រោម :

- កាត់បន្ថយការបញ្ចេញឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ
- កាត់បន្ថយឧស្ម័នចេញមកពីការបំលែងដីព្រៃទៅជាដីកសិកម្ម
- តួនាទីនៃការអភិរក្ស

- ការគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព
- បង្កើនបរិមាណកាបូនផ្ទុកនៅក្នុងព្រៃឈើ

និយមន័យនេះ អាចអោយប្រទេសភាគច្រើននៅលើសាកលលោកអាចចូលរួមអនុវត្តកម្មវិធី REDD+ នេះបាន បើទោះបីជាប្រទេសទាំងនោះ មានស្ថានភាពខុសៗពីគ្នាក៏ដោយ ។

## ស១៧: តើអ្នកណាខ្លះនឹងទទួលបានអត្ថប្រយោជន៍ពី REDD +?

**ច១៧:** នៅពេលដែលកម្មវិធី REDD ត្រូវបានបង្កើតឡើងដំបូងនៅក្នុងសន្និសីទលើកទី១៣ នៃបណ្តាភាគីជាសមាជិក (COP 13) ឆ្នាំ ២០០៧ កម្មវិធីនេះបានទាក់ទាញចំណាប់អារម្មណ៍ជាច្រើនពីប្រទេសដែលមានអត្រានៃការបាត់បង់ព្រៃឈើខ្ពស់។ ប្រទេសទាំងអស់នោះ មានសក្តានុពលយ៉ាងសំបើមក្នុងការកាត់បន្ថយនូវការបញ្ចេញឧស្មន័បណ្តាលមកពីការបាត់បង់ព្រៃឈើ នឹងអាចទាញយកផលប្រយោជន៍បានយ៉ាងច្រើន។ ស្ថិតនៅក្រោមកម្មវិធី REDD+ ដែលមានលក្ខណៈទូលំទូលាយជាងមុន ប្រទេស ដែលបានការពារព្រៃឈើ ប្រកបដោយប្រសិទ្ធិភាពរួចហើយនោះ ក៏ទទួលបានផលប្រយោជន៍ផងដែរ។ ការអនុវត្តប្រកបដោយនិរន្តភាព មានគោលបំណងជួយដល់ប្រជាជនក្រីក្រដូចជា ការអនុញ្ញាតិអោយសហគមន៏ប្រើប្រាស់ផលិតផលព្រៃឈើក៏ត្រូវបាន គេទទួលស្គាល់ និងលើកទឹកចិត្តផងដែរ។ ការឆ្ការព្រៃឈើក៏អាចមានការទទួលស្គាល់ផងដែរ។ ប្រសិនបើកម្មវិធី REDD+ ត្រូវបានគេយកមកពិភាក្សា មានប្រទេសជាច្រើនទំនងជានឹង គាំទ្របុផ្តល់សច្ចាប័ន ទៅលើកិច្ចព្រមព្រៀងនាពេលអនាគតនេះ។ ប៉ុន្តែ REDD+ តម្រូវអោយមានក្របខ័ណ្ឌ ការងារមួយ ដ៏ស្មុគស្មាញធ្វើអោយស្របទៅនឹងលក្ខខ័ណ្ឌផ្សេងៗ ដែលអាចឈានទៅរកការចំណាយប្រត្តិបត្តិការខ្ពស់ ។

## ស១៨: តើអ្នកណាកំពុងដោះស្រាយបញ្ហាប្រឈម ដែលមានលក្ខណៈបច្ចេកទេសរបស់កម្មវិធី REDD ហើយធ្វើឡើងតាមរបៀបណា?

**ច១៨:** មានកម្មវិធីសាកលចំនួន២ ដែលបានដំណើរការ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការអនុវត្តនូវយន្តការ REDD សម្រាប់នាពេលអនាគត:

១- មូលនិធិកម្មវិធី **REDD របស់អង្គការសហប្រជាជាតិ (UN-REDD):** មូលនិធិកម្មវិធី REDD របស់អង្គការសហប្រជាជាតិផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ស្តីពីបញ្ហាកាប់ព្រៃឈើ និងការធ្វើឱ្យព្រៃរេចរឹល។ កម្មវិធីនេះ ជួយគាំទ្រទៅលើការកសាងសមត្ថភាព បង្កើតយុទ្ធសាស្រ្តថ្នាក់ជាតិ និងវិធាន

ហិរញ្ញប្បទានសាកល្បង ព្រមទាំងការរៀបចំស្ថាប័នដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទៅលើការកាត់បន្ថយឧស្ម័ន ដែលចេញពីការបាត់បង់ព្រៃឈើ ។ ឥឡូវកម្មវិធី UN-REDD បានកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត ។ កម្មវិធី UN-REDD បានផ្ដល់ជំនួយនៅក្នុងការអនុវត្តគំរោងសាកល្បង គំរូនៅក្នុងប្រទេសខ្លះៗ ហើយ គឺដើម្បីត្រួតពិនិត្យមើលថាតើកម្មវិធី REDD មានដំណើរការជាក់ ស្តែងតាមរបៀបណា ?

២- កម្មវិធីទី២ឈ្មោះ គំរោងដៃគូរកាបោនព្រៃឈើ (Forest Carbon Partnership Facility-FCPF) របស់ធនាគារពិភពលោក បានផ្តួចផ្តើមជាសកល ដែលមានជាង ៣០ ប្រទេស ចូលរួមជាសមាជិកដោយរួមទាំងប្រទេសកម្ពុជាផងដែរ ។ គេសាកល្បងគំរោង REDD នៅក្នុងប្រទេសផ្សេៗគ្នា ដើម្បីមានបទពិសោធន៍ នៅក្នុងការអនុវត្ត។ គំរោងសាកល្បងនេះ អាចផ្តល់នូវព័តិមានទៅអ្នកចរចាទៅលើយន្តការ REDD នៅកំរិតអន្តរជាតិ ។

កម្មវិធីទាំងពីរនេះមានបេសកម្មក្នុងសម្របសម្រួល នៅពេលដែលប្រត្តិបត្តការណ៍នៅក្នុងប្រទេសដូចគ្នា និងរៀបចំការប្រជុំ ដើម្បីអោយអ្នកចូលរួមធ្វើការចែករំលែកនូវគំនិតយោបល់ ។ កម្មវិធីទាំងពីរ មានសកម្មភាពសាកល្បងអំពីយន្តការ រ៉េដ (REDD) ជាច្រើន ដែលកំពុងត្រូវបានអនុវត្តន៍នៅក្នុងប្រទេសផ្សេងៗគ្នា ដើម្បីធ្វើការយល់ ដឹងអោយកាន់តែប្រសើរឡើង អំពីរបៀបអនុវត្តគំរោង រ៉េដ (REDD) និង សាកល្បនូវភាព ដែលអនុវត្តន៍ទៅបាននៃវិធីសាស្រ្តផ្សេងៗគ្នា ។ លទ្ធផល ដែលទទួលបានពីកម្មវិធីទាំងនេះ នឹងជួយអ្នកចរចារនៅក្នុងអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ធ្វើការសំរេចចិត្តថាតើការបញ្ចេញឧស្ម័នកាបូនិច ដែលពាក់ព័ន្ធនឹងព្រៃឈើអាចត្រូវបានធ្វើការវាស់វែងបាន ដែរ រឺ ទេ និង ថាតើយន្តការ រ៉េដ (REDD) អាចធ្វើទៅបានដែរ រឺ ទេ ។

## ស១៩: តើការអនុវត្ត REDD Plus នឹងត្រូវចំណាយថវិកាចំនួនប៉ុន្មាន?

**ច១៩:** តាមរបាយការណ៍របស់លោកស្ទើន **(Stern Review)** អំពីសេដ្ឋកិច្ច នៃការប្រែប្រួលអាកាសធាតុបានបង្ហាញថាដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលចេញពីព្រៃឈើចំនួនពាក់កណ្តាល មុនឆ្នាំ ២០៣០ ត្រូវចំណាយអស់ទឹកប្រាក់ ១៧ ទៅ ៣៣ កោដិលានដុល្លា ជារៀងរាល់ឆ្នាំ ។

## សទ២០:   តើប្រាក់នេះបានមកពីណា?

**ចទ២០:** ប្រាក់នេះអាចបានមកពីគ្រោងការហិរញ្ញវត្ថុអន្តរជាតិ រឺ គំរោង REDD ថ្នាក់ជាតិ ។ ម្ចាស់ថវិកាមួយចំនួន បានប្រគល់លុយខ្លះសំរាប់គំរោងសាកល្បងលើទីផ្សាកាបូនស្ម័គ្រចិត្តរួចរាល់ហើយ ។ ប៉ុន្តែប្រាក់ភាគច្រើនដែលបានបែងចែកតាមរយៈគំរោងថវិការថ្មី រឺ ទីផ្សារ ដែលជាលទ្ធផលពីការចរចារបស់ UNFCCC នឹងមិនមានទេនៅក្នុងរយៈពេល ៣ ទៅ ៤ ឆ្នាំ ខាងមុខ ។

# សទ្ទានុក្រម

ភាពបន្សាំ (Adaptation) ៖ ការកែខៃអោយសមស្របដោយទង្វើរបស់មនុស្សនៅក្នុងធម្មជាតិ រឺប្រព័ន្ធមនុស្សលោក ដើម្បីខិតខំកាត់បន្ថយសេចក្តីអន្តរាយបណ្តាលមកពីការប្រែប្រួលបរិយាកាស ឬទាញយក ផលចំណេញពីការកើនឡើងកំដៅនៃពិភពលោក ។

ការដាំដុះព្រៃឈើ (Afforestation): ការបណ្តុះ និងការបង្កើតអោយមានព្រៃឈើថ្មីៗនៅលើដីទំនេរ ដែលមិនមានព្រៃឈើពីមុនមក ។

ការបំភាយឧស្ម័នដោយសកម្មភាពមនុស្ស (Anthropogenic Emissions) : ឧស្ម័នផ្ទះកញ្ចក់បំភាយឡើងពាក់ព័ន្ធជាមួយនឹងសកម្មភាពរបស់មនុស្សដូចជាតាមរយៈការបំផ្លាញព្រៃ រឺការធ្វើឱ្យព្រៃរិចរិលដោយសារការកាប់ឈើ ។

ជីវឥន្ធនៈ (Biofuels) : ឥន្ធនៈបានមកពីប្រភពជីវសាស្ត្រដែលអាចកើតឡើងវិញមានទំរង់ជាវត្ថុរឹង ឬរាវ ។ ដូងប្រេង អំពៅ និង សណ្តែកសៀងជា ឧទាហរណ៍ : នៃជីវឥន្ធនៈដែលមានទំនាក់ទំនងជាមួយការកាប់ព្រៃឈើ ។

ការកំណត់ និង ពាណិជ្ជកម្មលើការបំភាយឧស្ម័នផ្ទះកញ្ចក់ (Cap and Trade): ជារឿយៗផ្នែកទាំងពីរមានទំនាក់ទំនងជាប្រព័ន្ធ ក្នុងនោះ ‘cap’ គឺរដ្ឋាភិបាល បានដាក់ចេញ ជាកំហិតទៅលើការបំភាយនៃកាបូន និង ‘trade’ គឺរដ្ឋាភិបាលបាន បង្កើតទីផ្សារ ដើម្បីលក់ និង ទិញឥណទានឧស្ម័នផ្ទះកញ្ចក់ ។ ក្រុមហ៊ុន ដែលបំភាយឧស្ម័នផ្ទះកញ្ចក់តិចជាងចំនួន រឺបរិមាណ ដែលបានអនុញ្ញាតិអាចលក់ឥណទានដែលបានអនុញ្ញាតិនោះទៅអោយក្រុមហ៊ុនដទៃទៀត ។

ឧស្ម័នកាបូនិច (Carbon Dioxide) : ជាឧស្ម័នកើតឡើងដោយធម្មជាតិនៅក្នុងបរិយាកាស ។ ឧស្ម័ននេះត្រូវបានបង្កើតឡើងដោយសារចំហេះ (ឧ. ការរលួយ និងការដុតនូវឥន្ធនៈផូស៊ីលនិងជីវម៉ាស) ។ ឧស្ម័នកាបូនិចក៏អាចបំភាយចេញផងដែរ នៅពេលមានការផ្លាស់ប្តូរទៅលើការប្រើប្រាស់ដីធ្លី និង ក្នុងកំឡុងពេលដំណើរការឧស្សាហកម្ម ។

ទីផ្សារកាបូន (Carbon Markets) : ស្ថាប័នហិរញ្ញវត្ថុ និង យន្តការ ដែលអាចធ្វើការផ្លាស់ប្តូរឥណទានកាបូនដែលបានមកពីសកម្មភាពនៃការអនុវត្តគំរោង REDD ដែលត្រូវបានបញ្ជាក់ រឺផ្ទៀងផ្ទាត់។ ទីផ្សារការបូននេះអាចមានទំរង់ជា ទីផ្សារកាបូនស្មគ្រ័ចិត្ត (Voluntary Carbon Market) (ដែលត្រូវបានបង្កើតឡើងក្រោមទំរង់យន្តការទ្វេភាគី ដែលជាអ្នកធ្វើពាណិជ្ជកម្ម) ឬ ទីផ្សារយោគយល់គ្នា (Compliance Market) (វាគឺជាបទបញ្ញាស្របច្បាប់ ដើម្បីបំពេញគោលដៅក្នុងការកាត់បន្ថយការបំភាយឧស្មន័ផ្ទះកញ្ចក់ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងពហុភាគី) ។

ពាណិជ្ជកម្មកាបូន (Carbon Trading) :ការលក់ដូរនៃឥណទានកាបូន ដែលទទួលបានការបញ្ជាក់ឬលិខិតបញ្ជាក់បានមកពីគំរោង REDD នៅក្នុងទំរង់ជារូបិយវត្ថុ ។

អាងស្តុកកាបូន (Carbon Pool) : ជាប្រព័ន្ធដែលមានលទ្ធភាពក្នុងការប្រមូល និងបញ្ចេញកាបូន។ ឧទាហរណ៏: អាងស្តុកកាបូនគឺមានដូចជាជីវម៉ាស់ព្រៃឈើ ផលិតផលឈើ ដី និង បរិយាកាស។

ការស្រូបយកកាបូន (Carbon Sequestration): ការស្រូប និងផ្ទុកកាបូន ។ ដើមឈើស្រូបឧស្ម័នកាបូនិចហើយបញ្ចេញវិញនូវឧស្ម័នអុកស៊ីសែនតាមរយៈរស្មីសំយោគ ។ ដើមឈើក៏មានផ្ទុកកាបូននៅក្នុងជីវម៉ាស់ផងដែរ។

ការរក្សាទុកកាបូន (Carbon Sink): គឺជាដំណើរការ ឬយន្តការនៃការស្រូបយកឧស្ម័នកាបូនិចហើយ រក្សាទុកកាបូន ក្នុងទំរង់ជាសរីរាង្គ ដូចជា មហាសមុទ្រ ដី និង ព្រៃឈើ ។

ពន្ធលើកាបូន (Carbon Tax): ការដកហូតពន្ធពីអ្នកទាំងឡាយណា ដែលធ្វើការបញ្ចេញឧស្មន័កាបូនិចទៅក្នុងបរិយាកាស ។

ការអភិវឌ្ឍន៍យន្តការស្អាត (Clean Development Mechanism ) : គឺជាកម្មវិធីមួយ ដែលបណ្តាលប្រទេសឧស្សាហកម្មធ្វើការសំរេចនូវទិសដៅ នៃការបញ្ចេញចោលរបស់ពិធីសារក្យូតូ (Kyoto Protocol) នៅក្នុងមធ្យោបាយពីរក្រៅពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន មានជាអាទិ៍ : ពួកគេអាចធ្វើការវិនិយោគក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ឬក៏បង្កើនការរក្សាទុកនៃឧស្ម័នផ្ទះកញ្ចក់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

ការប្រែប្រួលអាកាសធាតុ (Climate Change): ការផ្លាស់ប្តូរនូវកត្តាឧតុនិយមជាក់លាក់ ដែលកំណត់អាកាសធាតុ និង ការប្រែប្រួលរបស់វា (ឧ. សីតុណ្ហភាព ទឹកភ្លៀង ល្បឿនខ្យល់បក់) ។

ផលចំណេញសងខាង រឺ សហប្រយោជន៍ (Co-benefits) : គឺជាផលចំណេញពីការអនុវត្តគម្រោងរ៉េដ (REDD) បន្ថែមលើការកាត់បន្ថយការបញ្ចេញចោលឧស្ម័នផ្ទះកញ្ចក់ ដូចជាការកាត់បន្ថយភាពក្រីក្រ ការការពារជីវចម្រុះ និងការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចព្រៃឈើ ។

សន្និសិទ្ធនៃបណ្តាភាគីជាសមាជិក (Conference of the Parties): ស្ថាប័នមួយ ដែលមានតួនាទីក្នុងការសំរេចចិត្ត ហើយក៏ជាសមាជិក ដែលបានផ្តល់សច្ចាប័ន ទៅដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ ។

ការបាត់បង់ព្រៃឈើ (Deforestation): ការប្រែប្រួលពីដីមានព្រៃឈើទៅដីអត់ព្រៃឈើ ។

សេវាកម្មនៃប្រព័ន្ធអេកូឡូស៊ី (Ecosystem Services) : ផលប្រយោជន៍ ដែលប្រព័ន្ធអេកូឡូស៊ីផ្តល់ ដល់ជីវិតមនុស្ស ។ ឧ. ព្រៃឈើផ្តល់ចំណីអាហារ ទឹក ឈើ និង សសៃអំបោះ។ សេវាកម្ម នៃប្រព័ន្ធអេកូឡូស៊ីធ្វើនិយ័តកម្មអាកាសធាតុ ទឹកជំនន់ ជម្ងឺ និងគុណភាពទឹក ហើយវាក៏ផ្តល់នូវសេវាកម្មកំសាន្ត ដូចជាកន្លែងសំរាកសោភ័ណភាព និង ជំនឿ ។

ប្រព័ន្ធអេកូឡូស៊ី (Ecosystem) : ការប្រមូលផ្តុំ រឺ សហគមន៍នៃសរីរាង្គ និងបរិស្ថានរបស់ពួកវា ។

ការឡើងកំដៅពិភពលោក (Global Warming): ការកើនឡើងជាមធ្យម នៃសីតុណ្ហភាពផែនដីពីមួយឆ្នាំទៅមួយឆ្នាំ ដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុ ។

ឥទ្ធិពលផ្ទះកញ្ចក់ (Greenhouse Effect) : នៅពេល ដែលឧស្ម័នដូចជា ឧស្ម័នកាបូនិចជាដើម ទប់ស្កាត់ថាមពលដែលបង្កើតដោយព្រះអាទិត្យ ហើយចាំងផ្លាតពីផែនដីក្នុងទំរង់ជាកំដៅ ដើម្បីគេចចេញពីបរិយាកាសផែនដី ។

ក្រុមអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (Intergovernmental Panel on Climate Change) : ការចូលរួមគ្នានៃកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ និងអង្គការឧតុនិយមពិភពលោក UNEP-WMO

ដែលជាអ្នកទទួលខុសត្រូវចំពោះការផ្តល់មូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស សំរាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

ពិធីសារក្យូតូ (Kyoto Protocol): គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយ ដែលគ្របដណ្តប់នៅក្នុងចន្លោះឆ្នាំ ២០០៨-២០១២ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។ ស្ថិតនៅក្រោមពិធីសារនេះ ប្រទេសឧស្សាហកម្មបានយល់ព្រមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អោយបាន ៥.២ ភាគរយ ពីកំរិតឆ្នាំ១៩៩០ ដើម្បីបង្អង់ល្បឿននៃការកើនឡើងកំដៅពិភពលោក ។

ការលេចធ្លាយ (Leakage): កើតឡើងនៅពេលការកាត់បន្ថយការបញ្ចេញចោលក្នុងតំបន់មួយនាំឱ្យកើនឡើងការបញ្ចេញចោលក្នុងតំបន់មួយទៀត ដូចជាគំរោង REDD ដែលការពារព្រៃក្នុងតំបន់មួយប៉ុន្តែមានការកាប់ឆ្ការព្រៃឈើកើនឡើងនៅតំបន់ផ្សេងទៀត ។ វាក៏ត្រូវបានគេស្គាល់ថា ជាការផ្លាស់កន្លែងនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

ភាពទទួលខុសត្រូវ (Liability) : កាតព្វកិច្ចនៃការអនុវត្តគំរោង REDD ឬក៏ប្រទេស ដែលអនុវត្តគំរោង REDD ត្រូវធានាថាការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះ ដែលត្រូវបានគេប្រមូលទុក រឺ ផ្តល់តំលៃអោយ គឺឋិតនៅជាអចិន្ត្រៃយ៍ ។

គារបន្ធូបន្ថយ (Mitigation) : សកម្មភាពដើម្បីកាត់បន្ថយការបញ្ចេញចោលឧស្ម័នផ្ទះកញ្ចក់ និងបង្កើនការរក្សារឹស្រូបយកកាបូនមានគោលបំណងកាត់បន្ថយទំហំនៃការកើនកំដៅពិភពលោក ។

ការទូទាត់ចំពោះសេវាកម្មបរិស្ថាន (Payments for Environmental Services): គំរោង ដែលអ្នកទទួលផលពីសេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីធ្វើការទូតទាត់ រឺ ចំណាយទៅអោយអ្នកគ្រប់គ្រង ដើម្បីធានានូវការបន្តនៃសេវាកម្មទាំងនោះ ។

រុក្ខជាតិពុក (Peat): គឺជាការប្រមូលផ្តុំនៃរុក្ខជាតិពុករលួយ ។ រុក្ខជាតិពុកកើតមានឡើងនៅក្នុងតំបន់ដីសើម ដែលរួមមាន ដីភក់ល្បប់ ឬដីទំនាប និង ព្រៃវាលភក់ ។

អចិន្ត្រៃភាព (Permanence) : សំដៅទៅលើថេរវេលា និង ភាពអាចត្រឡប់ក្រោយបាននៃការកាត់បន្ថយការបញ្ចេញចោលឧស្ម័នផ្ទះកញ្ចក់ ។

ព្រៃឈើដាំ (Planted Forest): ដីព្រៃឈើ ដែលបង្កើតឡើងតាមរយៈការដាំដោយកូនឈើ ឬ ការដាំដុះដោយគ្រាប់ពូជ។

ព្រៃព្រហ្មចារីរឺ ព្រៃបឋម (Primary Forest): ដី ដែលមានព្រៃប្រភេទរុក្ខជាតិក្នុងស្រុកយ៉ាងច្រើន និងមិនត្រូវបានប៉ះពាល់ដោយសកម្មភាពមនុស្ស និងកន្លែង ដែលដំណើរមិនត្រូវបានគេរំខាន ។

ការកាត់បន្ថយការបញ្ចេញចោលពីការកាប់ព្រៃឈើនិងការធ្វើឱ្យព្រៃរេចរឹល (REDD) : គឺជាយន្តការ ដែលមានគោលបំណងកាត់បន្ថយការបញ្ចេញចោលឧស្ម័នផ្ទះកញ្ចក់ដោយការទូទាត់សងប្រទេសទាំងឡាយណា ចំពោះការចៀសវាងពីការកាប់ឆ្ការព្រៃឈើ និងការធ្វើឱ្យព្រៃរេចរិល។

កាត់បន្ថយផលប៉ះពាល់នៃការកាប់ឈើ (Reduced Impact Logging):ការកាប់រំលំឈើ ដែលមានការត្រួតពិនិត្យ និងផែនការយ៉ាងយកចិត្តទុកដាក់ ដើម្បីឱ្យមានផលប៉ះពាល់តិចបំផុតលើបរិស្ថានជុំវិញ។ ការកាប់ឈើដោយកាត់បន្ថយផលប៉ះពាល់អាចបន្ថយផងដែរ នូវការបញ្ចេញឧស្ម័នកាបូនចេញមកពីសកម្មភាពកាប់ឈើ។

ការដាំព្រៃឡើងវិញ (Reforestation) : ការបង្កើតចំការព្រៃឈើដាំឡើងក្នុងតំបន់ដី ដែលមានព្រៃឈើពីមុន។

ការពិនិត្យឡើងវិញរបស់លោកស្ទើន (Stern Review) : គឺជារបាយការណ៍នៅក្នុងឆ្នាំ២០០៦ ដោយ Nicholas Stern សំរាប់រដ្ឋាភិបាលចក្រភពអង់គ្លេស ដែលពិនិត្យទៅលើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុចំពោះសេដ្ឋកិច្ចពិភពលោក។ ការពិនិត្យឡើងវិញរបស់លោកស្ទើន (Stern Review) មិនមែនជារបាយការណ៍លើកទីមួយនោះទេ ប៉ុន្តែវាប្រហែលជារបាយការណ៍មួយដ៏មានឥទ្ធិពលបំផុត ។

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលបរិយាកាស (UN Framework Convention on Climate Change): សិទ្ធិសញ្ញា១៩៩២ បានអំពាវនាវដល់ការធ្វើឱ្យមានលំនឹងនៃកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស នៅក្នុងកំរិតមួយដែលមុខជាមិនគ្រោះថ្នាក់ប៉ះពាល់ដល់អាកាសធាតុផែនដី។

# ហេតុការណ៍ និងតួរលេខ

## គំរបព្រៃ

- ផ្ទៃដីព្រៃឈើសរុបនៅក្នុងទូទាំងពិភពលោកមានប្រហែល ៤00 កោដិលានហិកតា តំណាងអោយជិត ៣0ភាគរយ នៃផ្ទៃដីដ៏ធំល្វឹងល្វើយនៅក្នុងផែនដី។ ប្រហែល ៥៦ភាគរយនៃ ផ្ទៃដីព្រៃឈើទាំងនេះ មានទីតាំងស្ថិតនៅក្នុងតំបន់ត្រូពិច និង អនុតំបន់ត្រូពិច ។
- គំរបព្រៃមានលក្ខណៈរាយប៉ាយមិនស្មើគ្នា។ មានតែប្រទេសចំនួន ៧ ប៉ុណ្ណោះ ដែលមានគំរបព្រៃឈើ ប្រហែល ៦0 ភាគរយ នៃគំរបព្រៃឈើទូទាំងពិពភលោក។ ប្រទេសចំនួន ២៥ មានគំរបព្រៃឈើ ប្រហែល ៨២ ភាគរយ និង សល់ ១៧0 ប្រទេសទៀត ដែលមានគំរបព្រៃឈើ ១៨ ភាគរយ។
- ព្រៃឈើដាំមានទំហំប្រហែល ៣,៨ ភាគរយនៃផ្ទៃដីព្រៃឈើសរុប ឬ ១៤0 លានហិកតា ។

## ការបាត់បង់ព្រៃ

- អត្រានៃការបាត់បង់ព្រៃឈើពិភពលោកសរុបត្រូវបានគេធ្វើការប៉ាន់ប្រមាណប្រហែល ៧,៣ លានហិកតានៅក្នុងមួយឆ្នាំបានគិតនៅក្នុងអំឡុងឆ្នាំ ២000-២00៥ ។
- នេះគឺបង្ហាញពីការថយចុះពីអំឡុងពេល ១៩៩0-២000 ដែលអត្រានៃការថយចុះព្រៃឈើគឺ ៨,៩ លានហិកតានៅក្នុងមួយឆ្នាំ ។
- បរិមាណនៃការបាត់បង់ព្រៃឈើដ៏ខ្ពស់បំផុតនេះ បានកើតឡើងនៅអាមេរិកខាងត្បូង ដោយមានការបាត់បង់ព្រៃឈើ ៤,៣ លានហិកតានៅក្នុងមួយឆ្នាំ បន្ទាប់មកទៀតគឺ អាហ្វ្រិក ដោយមានការបាត់បង់ព្រៃឈើ ៤លានហិកតានៅក្នុងមួយឆ្នាំ។

## ព្រៃឈើ និងជីវភាពរស់នៅ

- ប្រជាជនច្រើនជាង មួយរយកោដិលាននាក់ ធ្វើការរស់នៅពឹងអាស្រ័យទៅលើព្រៃឈើសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ។
- ប្រជាជនច្រើនជាង ពីររយកោដិលាននាក់ ដែលស្មើរនឹងមួយភាគបី នៃប្រជាជនពិភពលោកប្រើប្រាស់ថាមពល ជីវម៉ាសច្រើនបំផុត នោះគឺឈើថាមពល ដើម្បីចំអិនអាហារ និងបង្កើតកំដៅនៅក្នុងផ្ទះរបស់ពួកគេ។
- ប្រជាជនរាប់រយលាននាក់បានពឹងអាស្រ័យទៅលើឱសថបុរាណ ដែលបានពីការប្រមូលចេញពីក្នុងព្រៃ។

- នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លះនៅក្នុងចំណោម ៦០ ប្រទេស ការបរបាញ់ និង ការនេសាទត្រីនៅក្នុងតំបន់ព្រៃឈើបានផ្គត់ផ្គង់ច្រើនជាងមួយភាគប្រាំនៃតំរូវការសារធាតុប្រូតេអ៊ីន ។

## ព្រៃឈើ និង សេដ្ឋកិច្ច

- នៅក្នុងឆ្នាំ ២០០៣ ពាណិជ្ជកម្មអន្តរជាតិនៅក្នុងឧស្សាហកម្ម ឈើអារ សាច់ឈើ ក្រដាស និង ក្តារ បានមានចំនួនប្រមាណ ១៥០ ០០០ កោដិលានដុល្លា ឬ ច្រើនជាង ២ភាគរយនៃពាណិជ្ជកម្មពិភពលោក។ ការប្រទេសអភិវឌ្ឍន៍មានចំនួនពីរភាគបី នៃផលិតកម្ម និងការប្រើធនធានព្រៃឈើនេះ។
- នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ សហគ្រាសព្រៃឈើបានផ្តល់យ៉ាងហោចណាស់ មួយភាគបីនៃកំលាំងពលកម្ម ទាំងអស់ក្រៅពីការងារកសិកម្ម និងបង្កើតប្រាក់ចំណូលតាមរយៈការលក់ផលិតផលឈើ ។
- តំលៃពាណិជ្ជកម្មនៅក្នុងផលិតផលជាអនុផលព្រៃឈើត្រូវបានគេធ្វើការប៉ាន់ប្រមាណប្រហែលជា ១១លាន ដុល្លា ។ ផលិតផលទាំងនេះរួមទាំងរុក្ខជាតិជាឱសថ ផ្សិត គ្រាប់ផ្លែឈើព្រៃ ជ័រព្រៃ ។

## ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

- គេបានធ្វើការប៉ាន់ប្រមាណថា ១,៧ កោដិតោននៃឧស្ម័នកាបូនិចបានបញ្ចេញជាប្រចាំឆ្នាំទៅក្នុងបរិយាកាសដោយសារតែមានការប្រែប្រួលនៃការប្រើប្រាស់ដី។ ភាគច្រើនគឺបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ត្រូពិក។
- ការកាប់បំផ្លាញព្រៃឈើបានបំភាយឧស្ម័នផ្ទះកញ្ចក់ប្រហែលជា ២០ភាគរយនៃការការបំភាយឧស្ម័នផ្ទះកញ្ចក់ទូទាំងពិភពលោក គឺច្រើនជាងការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលចេញវិស័យដឹកជញ្ជូនលើពិភពលោក ដែលប្រើប្រាស់ប្រេងឥន្ធនះ។